០៨/០៣/២០២៦ **ព្រឹត្តិប័ត្រសាលា** លេខ ៣

# SPRING PARKS PRIMARY SCHOOL

*Learning and Growing - Safety - Together*

**West Campus - Administration**
24 Erica Street, Springvale 3171 ☎ 9546 6402

**Valley Campus**
27-39 Clarke Road, Springvale South 3172 ☎ 9547 3222

✉ spring.parks.ps@education.vic.gov.au springparksps.vic.edu.au

គោរព | ចូលរួម | លទ្ធផល | សហគមន៍ | សង្ឃឹម



ជំរាបមាតាបិតា,

កាលពិថ្ងៃព្រហស្បត៏មុន,យើងខ្ញុំបានប្រារព្ធពិធីបុណចូលឆ្នាំចិន ,យើងខ្ញុំបានប្រារព្ធពិធីបុណ្យចូលឆ្នាំចិននៅសាខាទាំងពីរ, ហើយនេះពីតជាថ្ងៃមួយដ៏អស្ចារ្យ។សូមអរគុណជាពន្លឹកដល់ Ms Sally Hou ដែលបានចាត់ចែងពិធីបុណ្យអបអរសាទរដ៏មហោឡារឹកនេះ។ខ្ញុំផ្ទាល់បានឮសិស្សមួយចំនួននិយាយថា នេះជាថ្ងៃមួយដ៏អស្ចារ្យជាងថ្ងៃណាទាំងអស់ ",នេះជាចម្លើយមួយដែល យើងទាំងអស់គ្នាចង់ស្តាប់។ សូមអរគុណដល់មាតាបិតាដែលបាមកជួយពេញមួយថ្ងៃនិងអ្នកដែលបានមកជួយនៅពេលព្រឹក។ ការចូលរួមរបស់លោកអ្នកបានធ្វើឲ្យការអបអរសាទរក្នុងសហគមន៏យើង មានភាពពិសេសសំរាប់កុមារ។

តាមSentral, ការតែងតាំងនាមជ្រើសរើសសមាជិកក្រុមប្រឹក្សាបានបើកហើយ។ បើលោកអ្នកមានចំណូលចិត្តចូលរួមជាចំណែកដើម្បីតម្រង់ទិសដៅយុទ្ធសាស្រ្តនិងការគ្រប់គ្រងសាលា,សូមមកការិយាល័យនៃសាខាណាមួយដើម្បីយកបណ្ណ័ៈ ឈ្មោះតែងតាំង។ក្រុមប្រឹក្សាសាលាមានតួរនាទីយ៉ាងសំខាន់ក្នុងការកំណត់ចក្ខុវិស័យរបស់សាលា,ការអនុម័តគោលនយោបាយនិងការគាំទ្រការត្រួតពិនិត្យហិរញ្ញវត្ថុដ៏ល្អិតល្អន់។

សូមរំឮកថា,ថ្ងៃច័ន្ទទី៩/៣គឺជាថ្ងៃបុណ្យសាធារណៈ,កុមារសម្រាក១ថ្ងៃ។នៅថ្ងៃសុក្រទី១៣/៣,សាលានឹងមានកិច្ចប្រជុំគំរោងកម្មវិធីសិក្សា,សិស្សសំរាក១ថ្ងៃ។ ក្នុងថ្ងៃនេះ សាលានឹងធ្វើការជាមួយនឹងអ្នកឯកទេសខាងលេខនព្វន្ត Brad Nguyen. Brad នឹងគាំទ្រគ្រូសាលាយើងដើម្បីពង្រឹងបន្ថែមនូវវិធីសាស្រ្តខាងលេខនព្វន្តនៃសាលាទាំងមូលដើម្បីធនាដល់ការអនុវត្តឲ្យស្របនឹងគ្រប់កំរឹតថ្នាក់។ការរៀនសូត្រដ៏ជំនាញនេះស្របនឹងផែនការអនុវត្តប្រចាំឆ្នាំនិងការប្តេជ្ញាចិត្តដើម្បីបន្តឲ្យបានប្រសើរថែមទៀងអំពីលទ្ធផលក្នុងការរៀននិងបង្រៀន។

សប្តាហ៏ក្រោយគឺការប្រឡងសាក NAPLAN នៃថ្នាក់ទី ៣និងទី ៥ យើងខ្ញុំសូមលើកទឹកចិត្តគ្រួសារឲ្យកុមារយល់ឲ្យបានបានត្រឹមត្រូវអំពីការប្រឡងនេះ។NAPLAN គឺគ្រាន់ជាភាគតូចមួយមួយក្នុងការរៀនសូត្រហើយពុំមែនជាអ្វីម្យ៉ាងគួរឲ្យព្រួយបារម្ភណ៏នោះទេ។ ការរៀបចំដ៏ល្អបំផុតគឺពេលយប់គេងឲ្យបានល្អ,ស្រស់ស្រួបពេលព្រឹកដ៏ឆ្ងាញ់ហើយមានជីវជាតិ,ហើយមកសាលាឲ្យទាន់ម៉ោងនិងក្នុងស្មារតីដ៏ស្ងប់ស្ងាត់។ បុគ្គលិកសាលានឹងធ្វើឲ្យកុមារមានអារម្ភណ៏ បានជួយគាំទ្រនិងមានទំនុកចិត្តជានិច្ចនៅពេលប្រឡងសាក។

កិច្ចសម្ភាសន៏រវាងមាតាបិតានិងគ្រូនឹងចាប់ផ្តើមនៅសប្តាហ៏ក្រោយ,យើងខ្ញុំសង្ឃឹមថាគ្រួសារនឹងអញ្ជើញមកឲ្យបានកុះករក្នុងថ្ងៃនេះ។ កិច្ចប្រជុំក្នុងថ្ងៃនេះគឺជាឱកាសដ៏សំខាន់ដើម្បីពិគ្រោះអំពីការជឿនលឿនរបស់កូនលោកអ្នក,អបអរសាទរលទ្ធផលនៃការរៀនហើយពង្រៃពង្រឹកភាគីភាពរវាងសាលានិងគ្រួសារ។

ក្នុងរយះពេលប៉ុន្មានសប្តាហ៏កន្លងមកនេះ,ខ្ញុំបានដឹកនាំដំណើរទស្សនកិច្ចជុំវិញសាលាជាច្រើន,ហើយពិតជារីករាយណាស់ដែលបានបង្ហាញថ្នាក់រៀន,កម្មវិធីសិក្សានិងបរិយាកាសសិក្សានៃសាលាយើង។ខ្ញុំរីករាយណាស់បើបានដឹកនាំទស្សនកិច្ចជុំវិញសាលាថែមទៀត។បើលោកអ្នកដឹងគ្រួសារណាមានកូនចាប់ផ្តើមចូលរៀននៅឆ្នាំក្រោយ,សូមលើកទឹកចិត្តឲ្យគេមកទាក់ទងនឹងការិយាល័យសាលាដើម្បី កក់ពេលដើរមើល-សាលា។ពាក្យសំដីពីមាត់មួយទៅមាត់មួយពិតជាមានឥទ្ធិពលណាស់,ហើយខ្ញុំមានមោទនភាពចំពោះសហគមន៏សាលាដែលយើងទាំងអស់បានរួមសាងសង់ឡើង។ សូមអរគុណ។

Phil O'Reilly :នាយកសាលា

## កំណត់ប្រចាំថ្ងៃ: 04/03/2026:

០៨/៣: ថ្នាក់ទី៨ធ្វើដំណើសិក្សានៅ Burden Park
០៩/៣: សិស្សសំរាក១ថ្ងៃៈបុណ្យការងារ
១០/៣: កិច្ចសម្ភាសន៏រវាងមាតាបិតានិងគ្រូ
១១/៣: ប្រឡងសាក NAPLAN–ខាងសរសេរ
ថ្នាក់ទី២ធ្វើដំណើរសិក្សានៅអាងត្រី
១២/៣: ប្រឡងសាក NAPLAN–ខាងអាន
អនុសញ្ញាភាសា
១៣/៣: សិស្សសំរាក១ថ្ងៃ: ថ្ងៃគំរោងកម្មវិធីសិក្សា
១៦/៣: ប្រឡងសាក NAPLAN–ខាងគណិតសាស្រ្ត
១៨/៣: កុមារថ្នាក់ទី៨ទៅសួនរុក្ខសាស្រ្ត
១៩/៣: ថ្នាក់ទីធ្វើដំណើរសិក្សានៅ Bounce
២០/៣: ប្រកួតកីឡាអត្តពលកម្មប្រចាំសង្កាត់
ថ្នាក់ទី១ធ្វើដំណើរសិក្សានៅ**Alex Wik**
៣១/៣: ថ្នាក់ទី៥ទៅលេងសួនសត្វម៉ែលប៊ុន
០២/៤: ថ្ងៃចុងក្រោយនៃត្រីមាសទី១(បញ្ចប់នៅម៉ោង២:៣០):គោរពទង់ជាតិរួមនៃសាខាទាំងពីរៈម៉ោង១០–នៅសាខាខាងលិច

**សាលាយើងមានក្តីសោមនស្សជាគូរភាគីនឹង : Food Bank,Ardoch,Woodleigh School, OSH Club,Berry Street,Ed Connect**

# ព្រឹត្តិការណ៍នៃបុណ្យចូលឆ្នាំចិន

កាលពិថ្ងៃព្រហស្បត៍មុន,សាលាយើងមានកត្តិយសដើម្បីប្រារព្វពីធីចូលឆ្នាំចិនសំរាប់សហាគមន៏សាលាយើង។កុមារបានសម្ដែងចម្រៀងដែលបានរៀននៅក្នុងម៉ោងរៀនអក្សរចិន,ស្វែងយល់ពីប្រពៃណីយ៏ដ៏សម្បូរបែបនៃល្ខោនបុរាណចិន,ហើយបានរួមក្នុងសកម្មភាពវប្បធម៍ជាច្រើនដូចជាការធ្វើមីនិងភ្លក់រស់ជាតិមីការសរសេរអក្សរផ្ទង់ចិនដោយប្រើជក់និងការប្រកួតចាប់ចង្កឹះជាដើម។នេះជាថ្ងៃដ៏អស្ចារ្យមួយពោរពេញទៅដោយការរៀនសូត្រ,សំណើចនិងការស្វែងយល់បវ្បធម៍។



ដោយមានការគាំទ្រពីអ្នកគ្រប់គ្នា,ព្រឹត្តិការណ៏នេះបានទទួលជោគជ័យដ៏ត្រចះត្រចង់។ខ្ញុំសូមសម្ដែងអំណរអរគុណដល់សហាប្រតិបត្តិការណ៏និងការគាំទ្រពីលោកអ្នក។

ជាការល្អណាស់ដោយបានឃើញកុមារស្លៀកពាក់ប្រពៃណីយឬសម្លៀកបំពាក់ឬសម្លៀកបំពាក់ពេលបុណ្យជាពណ៏ក្រហមនិងលឿង។សូមអរគុណដល់មាតាបិតាដែលបានចំណាយពេលដ៏មានតម្លៃរបស់ខ្លួនមកជួយដាំនិងជួយកិច្ចការដទៃក្នុងថ្ងៃនេះ។ការគាំទ្ររបស់លោកអ្នកធ្វើឲ្យព្រឹត្តិការណ៏នេះមានន័យដ៏ពិសេស។សូមអរគុណម្ដងទៀតចំពោះការជួយធ្វើឲ្យបុណ្យនេះជាប្រឹត្តិការណ៏មួយមិនអាចបំភ្លេចបាន។









# ក្របខ័ណ្ឌសុវត្ថិភាពកុមារ

សាលាបឋមសិក្សាស្ព្រីងប៉ាកបានប្ដេជ្ញាផ្ដល់បរិយាកាសិក្សាក្នុងសាលាប្រកបដោយសេចក្ដីសុខហើយកុមារមានអារម្មណ៏សុវត្ថិភាព។

ក្របខ័ណ្ឌសុវត្ថិភាពកុមាររបស់យើងមានរួមទាំងគោលនយោបាយ,វិន័យនិងរបៀបវារៈដែលពន្យល់ពីវិធីសាស្ត្រយើងខ្ញុំក្នុងការជួយគាំទ្រ,រក្សាសុវត្ថិភាពនិងសុខុមាលភាពរបស់សិស្សសាលាយើងហើយការពារកុមារជៀសវាងពីគ្រោះថ្នាក់។ឯកសារទាំងនេះអាចរកឃើញនៅគេហទំព័រសាលា: www.springparksps.vic.edu.au

ក្រៅពីនេះយើងខ្ញុំក៏សូមប្ដេជ្ញាបន្តធ្វើឲ្យបានប្រសើរឡើងថែមអំពីក្របខ័ណ្ឌសុវត្ថិភាពកុមារនៃសាលា។
ក្នុងពេលបច្ចុប្បន្ននេះ,យើងខ្ញុំកំពុងពិនិត្យមើលឡើងវិញពីគោលនយោបាយសុវត្ថិភាពរបស់កុមារនិងការអនុវត្តន៏ដើម្បីធានាថាទាន់សម័យនិងមានប្រសិទ្ធិភាព។សិស្សនិងមាតាបិតាជាគូរភាគីដ៏សំខាន់នៃដំណើរការណ៏នេះ។ យើងខ្ញុំស្វាគមន៏មតិនិងយោបល់អំពីរបៀបដែលអាចធ្វើឲ្យសុវត្ថិភាពនិងសុខុមាលភាពរបស់កុមារឲ្យរឹតតែប្រសើរថែម។
បើលោកអ្នកមានមណើអ្វីម្យ៉ាងឬយោបល់,សូមទាក់ទងនឹង Phil O’Reilly តាមរយ;ទូរស័ព្ទលេខ: ៩៥៨៦៦៨០២














## ថ្នាក់ទី 3 A អបអរសាទរបុណ្យចូលឆ្នាំចិន







# ថ្នាក់ទី៣ត្រូវការជំនួយពីលោកអ្នក!

យើងកំពុងប្រមូលយកគម្របដប, បំពង់ក្រដាស់កាតុង,និងធុងកាតុង តូចៗសំរាប់ធ្វើគំរូដើមគ្រឿងដឹកនាំ



សូមយកមកឲ្យ Ms Cooper & Ms Woodhams ឬសិស្សណាមួយនៃថ្នាក់ទី 3A & 3L

សូមកុំយកប្រអប់ដាក់ពងមាន់ឬបំពង់ក្រដាស់បង្គន់

សូមអរគុណ






## Stars Of The Week

### West Campus

| Grade | Week 4 | Week 5 |
|---|---|---|
| FA | Finan– Sonita | Aylin-Ariella |
| 1A | Mikhail | Bondith |
| 2A | Ashlan | |
| 3A | Valey | Ishmeet |
| 4A | Paul | Elliah |
| 5A | Tam | |
| 6A | Hayden | |
| Visual Arts | Vinnson | |
| PE | Varaden | Noah |
| Mand. | | |
| Perf.Arts | | |

### Valley Campus

| | Week 4 | Week 5 |
|---|---|---|
| FL | Jessica | Rayyan |
| 1L | Jason | Jamie |
| 2L | Philomena | Jayden D |
| 3L | Reha | Jayden |
| 4L | Ryandeep | Chelsea |
| 5L | Mandy-Hannah | Ekin |
| 6L | Chanlida | Sarita |
| Visual Arts | Victor | Peter |
| PE | Ezekiel | Allen |
| Mand. | Luke | |
| Perf.Arts | Wayne | Faleeshiya |